# សេចក្តីថ្លែងការរួមរបស់ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និង
# អង្គការសុខភាពពិភពលោក (WHO)

**មិនទាន់មានការបញ្ជាក់ថាមានករណីជំងឺគ្រុនផ្តាសាយប្រភេទ A (H1N1) នៅឡើយទេ នៅក្នុងប្រទេសកម្ពុជា**

ក្រសួងសុខាភិបាល, ភ្នំពេញ, ថ្ងៃសុក្រទី ២២ ខែឧសភា ឆ្នាំ ២០០៩

ក្រសួងសុខាភិបាលសូមជំរាបថា គិតមកដល់ថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០៩ នេះ គ្មានករណីជំងឺគ្រុនផ្តាសាយប្រភេទ A (H1N1) ត្រូវបានរកឃើញថាបានកើតមានឡើងនៅក្នុងប្រទេសទេ ។

ក្រសួងសុខាភិបាលបានទទួលនូវការជូនដំណឹងជាផ្លូវការពីស្ថានទូតកូរ៉េថា មានមនុស្ស ៣នាក់ បានធ្វើដំណើរពីសហរដ្ឋអាមេរិកទៅកាន់ប្រទេសកូរ៉េ នៅលើជើងយន្តហោះជាមួយនឹងអ្នកធ្វើដំណើរម្នាក់ទៀត ដែលនៅពេលក្រោយមក ត្រូវបានគេរកឃើញថាបានឆ្លងមេរោគជំងឺគ្រុនផ្តាសាយប្រភេទ A (H1N1) ។ បន្ទាប់មកអ្នកទាំង ៣នាក់នោះ បានជិះយន្តហោះផ្សេងមួយទៀត មកកាន់ទីក្រុងភ្នំពេញ នៅថ្ងៃអាទិត្យទី ១៧ ខែឧសភា ឆ្នាំ ២០០៩ ។

នៅក្នុងពេលមកប្រទេសកម្ពុជា មនុស្សទាំងបីនាក់នោះ មិនបានបង្ហាញអោយឃើញនូវអាការៈរោគគ្រុនផ្តាសាយទេ ។ នៅក្នុងពេលឥឡូវនេះ មន្ត្រីក្រសួងសុខាភិបាលកំពុងធ្វើការតាមរកអ្នកដំណើរទាំង ៣នាក់នោះ ដើម្បីធ្វើការវាយតំលៃអំពីសុខុមាលភាពរបស់គេ និងធ្វើតេស្តទៅលើពួកគេ ។

ក្រសួងសុខាភិបាល កំពុងធ្វើការងារយ៉ាងជិតស្និទ្ធជាមួយរដ្ឋអំណាចដែលពាក់ព័ន្ធទាំងអស់ និងកំពុងបន្តតាមដានស្ថានការណ៍ប្រកប ដោយការយកចិត្តទុកដាក់ ។

យោងទៅតាមផែនការថ្នាក់ជាតិសំរាប់ការរាតត្បាតជាសាកលនៃរាជរដ្ឋាភិបាលកម្ពុជា ក្រសួងសុខាភិបាលគឺជាប្រភពផ្លូវការតែមួយគត់នៃព័ត៌មានដែលទាក់ទងទៅនឹងស្ថានភាពជំងឺគ្រុនផ្តាសាយប្រភេទ A (H1N1) នៅក្នុងប្រទេស ហើយក្រសួងសុខាភិបាលនឹងបន្តធ្វើការផ្សព្វផ្សាយដល់សាធារណៈជនប្រសិនបើមាន និង នៅក្នុងពេលដែលករណីជំងឺគ្រុនផ្តាសាយប្រភេទ A (H1N1) ត្រូវបានរកឃើញនៅក្នុងប្រទេសកម្ពុជា តាមរយៈ website របស់ខ្លួនៈ www.cdcmoh.gov.kh និងតាមរយៈសេចក្តីថ្លែងការទៀងទាត់ របស់ខ្លួន ជូនដល់បណ្តាញសារព័ត៌មាន ។

ក្រសួងសុខាភិបាល សូមធ្វើការរំលឹកដល់សាធារណៈជនទាំងអស់ អោយធ្វើការអនុវត្តនូវវិធានការអនាម័យល្អគ្រប់ពេលវេលាៈ

១. គ្របមាត់របស់អ្នកដោយក្រដាសអនាម័យ នៅក្នុងពេលដែលអ្នកក្អក ឬកណ្តាស
២. លាងសំអាតដៃរបស់អ្នកជារឿយៗដោយប្រើសាប៊ូ
៣. កុំខាកស្តោះនៅក្នុងទីសាធារណៈ

បុគ្គលណាមួយដែលបានធ្វើដំណើរមកពីតំបន់ដែលមានការឆ្លងរោគនៅក្នុងរយៈពេល ៧ថ្ងៃកន្លងទៅ និងមានអាការៈរោគគ្រុនក្តៅ ដោយមានការក្អក ឈឺបំពង់ក ឬដង្ហើមញាប់ សូមមេត្តាធ្វើការទាក់ទងភ្លាមៗទៅកាន់ខ្សែទូរស័ព្ទទាន់សភាពការណ៍របស់ក្រសួងសុខាភិបាល ដែលមានលេខៈ **០១២ ៤៨៨ ៩៨១** ឬ **០៨៩ ៦៦៩ ៥៦៧** ដើម្បីទទួលបាននូវដំបូន្មានបន្ថែម ។

***

សំរាប់ព័ត៌មានបន្ថែមទៀត សូមធ្វើការទាក់ទងៈ

**ក្រសួងសុខាភិបាល**

វេជ្ជបណ្ឌិត **សុខ ទូច**

ទូរស័ព្ទៈ +៨៥៥ ០១២ ៨៥៦ ៨៤៨

វេជ្ជបណ្ឌិត **លី សុវណ្ណ**

ទូរស័ព្ទៈ + ៨៥៥ ០១២ ៨២៥ ៤២៤

**អង្គការសុខភាពពិភពលោក**

វេជ្ជបណ្ឌិត Mike O'Leary: ទូរស័ព្ទៈ +៨៥៥ ០២៣ ២១៦ ៦១០

វេជ្ជបណ្ឌិត Nima Asgari: ទូរស័ព្ទៈ +៨៥៥ ០១២ ៤៤៣ ៨៧៧